# ព្រះរាជក្រឹត្យ

នស/រកត/០៤១៧/៥៩២

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧១៧/៥៨៦ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០១៧ ស្ដីពីការកែសម្រួលមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា និងមាត្រា៤ថ្មី, មាត្រា១០ថ្មី, មាត្រា១១ថ្មី, មាត្រា១២ថ្មី និងមាត្រា២០ថ្មី នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្ដីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះ មានគោលបំណងពង្រឹង និងលើកតម្កើងស្ថាប័នរាជបណ្ឌិត្យសភាកម្ពុជា លើមុខងារថែរក្សា និងអភិវឌ្ឍធនធានពុទ្ធិ និងបញ្ញាញាណ ប្រកបដោយបូរណភាព គុណានុភាព និងកិត្យានុភាព នៅទូទាំងព្រះរាជាណាចក្រកម្ពុជា និងឆាកអន្តរជាតិ។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលហៅថា **ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ** ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសមាជិក និងតួអង្គពាក់ព័ន្ធនៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា៤.-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានកិត្តិយស នៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

**មាត្រា៥.-**

ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ មានប្រធាន មួយរូប និងអមដោយអនុប្រធាន ពីររូប ដែលត្រូវជ្រើសរើសចេញពីក្នុងចំណោមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា។

ប្រធានរាជបណ្ឌិត្យសភាកម្ពុជា បំពេញតួនាទីជាអនុប្រធានប្រចាំការ នៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ និងជាសេនាធិការរដ្ឋបាល ជូនក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

ប្រធាន និងអនុប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី។

សមាជិកពេញសិទ្ធិនៃរាជបណ្ឌិត្យសភាកម្ពុជា មានចំនួនកំណត់មិនលើសពី ៧៩ រូប។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា៦.-**

អនុប្រធាន និងសមាជិកក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ត្រូវចូលរួមប្រជុំសាមញ្ញប្រចាំឆមាស និងប្រជុំវិសាមញ្ញ តាមការចាំបាច់ តាមការអញ្ជើញរបស់ប្រធាន។

ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធានដែលទទួលបានការប្រគល់សិទ្ធិ ត្រូវបំពេញមុខងារជាប្រធានស្ដីទី លើការងារអញ្ជើញ និងដឹកនាំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

**មាត្រា៧.-**

ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យដឹកនាំមហាសន្និបាតវិសាមញ្ញ និងសាមញ្ញ នៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ ទទួលខុសត្រូវដឹកនាំការងាររបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៅចន្លោះពីកិច្ចប្រជុំ ឬមហាសន្និបាតមួយ ទៅកិច្ចប្រជុំ ឬមហាសន្និបាតមួយទៀត។

**មាត្រា៨.-**

ប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ អាចមានជំនួយការ មិនលើសពី ៣ រូប។

អនុប្រធានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ អាចមានជំនួយការមិនលើសពី ២ រូប។

សមាជិកក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ អាចមានជំនួយការ ១ រូប។

**មាត្រា៩.-**

ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- លើកសំណើកំណត់ក្របខ័ណ្ឌគោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា
- លើកសំណើផ្ដល់គោរមងារនៃរាជបណ្ឌិត្យសភាកម្ពុជា ជូនឥស្សរជននានា
- ពិនិត្យ និងអនុម័តលើផែនការយុទ្ធសាស្ត្ររយៈពេលវែង និងមធ្យម ដែលស្នើឡើងដោយរាជបណ្ឌិត្យសភាកម្ពុជា ដើម្បីតម្រង់ទិសការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍវិទ្យាសាស្ត្រ
- ពិនិត្យ និងអនុម័តកម្មវិធី និងលទ្ធផល នៃការប្រកួតប្រជែងស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ ក្នុងវិស័យជាអាទិ៍វប្បធម៌ សិល្បៈ អក្សរសាស្ត្រ ទស្សនវិជ្ជាសង្គមកិច្ច សេដ្ឋកិច្ច បច្ចេកវិទ្យា សហគ្រិនភាព និងឧស្សាហកម្ម
- ផ្ដល់ពានរង្វាន់ដល់ស្នាដៃស្រាវជ្រាវវិទ្យាសាស្ត្រ និងនវានុវត្តន៍ ក្នុងវិស័យជាអាទិ៍វប្បធម៌ សិល្បៈ អក្សរសាស្ត្រ ទស្សនវិជ្ជាសង្គមកិច្ច សេដ្ឋកិច្ច បច្ចេកវិទ្យា សហគ្រិនភាព និងឧស្សាហកម្ម
- បោះឆ្នោតជ្រើសរើសសមាជិកពេញសិទ្ធិ សមាជិកបម្រុង សមាជិកសមាគមិក សមាជិកកិត្តិយស និងសមាជិកឆ្លើយឆ្លង នៃរាជបណ្ឌិត្យសភាកម្ពុជា។

**មាត្រា១០.-**

ក្របខ័ណ្ឌគោរមងារ នៃរាជបណ្ឌិត្យសភាកម្ពុជា ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី។

**មាត្រា១១.-**

លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងកិច្ចដំណើរការរបស់ក្រុមសមាជិកពេញសិទ្ធិ នៃរាជបណ្ឌិត្យសភាកម្ពុជា ដែលកំពុងអនុវត្ត ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានថ្មី មកជំនួស។

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា១២.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០១៧

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកត/០៨១៧/៦០១

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៥៩៤ ស.ណ

**សំណៅចម្លងចេញពីច្បាប់ដើម មានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**